ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអភិវឌ្ឍន៍ជនបទ

លេខ: ០១៣/៤៤/១០ ក.អ.ជ.សរ.ទ

រាជធានីភ្នំពេញ ថ្ងៃទី០៤..ខែមិថុនា.ឆ្នាំ២០១០

# សេចក្តីសម្រេច

## ស្តីពីការបង្កើតក្រុមការងារបច្ចេកទេសវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ

## រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០១ ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- យោងចំណារឯកភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៨ ខែសីហា ឆ្នាំ២០០៧ ស្តីពីការអនុញ្ញាតឱ្យក្រសួងអភិវឌ្ឍន៍ជនបទបង្កើតក្រុមការងារបច្ចេកទេសវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ

## ស ម្រេ ច

**ប្រការ ១ :** បង្កើតក្រុមការងារបច្ចេកទេសវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ - អក្សរកាត់ **ក.ក.ប.ផ.ទ.អ** (Technical Working Group on Rural Water Supply, Sanitation and Hygiene [TWG-RWSSH ] ) ដើម្បីធ្វើឱ្យវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ បានប្រសើរឡើង ក្នុងការឆ្លើយតបទៅនឹងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។

**ប្រការ ២ : ក.ក.ប.ផ.ទ.អ** ជាក្រុមការងារអន្តរស្ថាប័ន រវាងស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល និងស្ថាប័នអ្នកផ្តល់ជំនួយ ដែលជាដៃគូអភិវឌ្ឍន៍លើវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ។ **ក.ក.ប.ផ.ទ.អ** មានសមាសភាពដូចខាងក្រោមនេះ :

| | | |
|---|---|---|
| ១. ឯកឧត្តម **ជា សុផារ៉ា** | រដ្ឋមន្ត្រី ក្រសួងអភិវឌ្ឍន៍ជនបទ | ប្រធាន |
| ២. លោក **Jan Willem Rosenboom** | ប្រធានក្រុម WSP-Cambodia | ប្រធានសម្របសម្រួលភាគីដៃគូអភិវឌ្ឍន៍ |
| ៣. ឯកឧត្តម **ទ្រី មេង** | រដ្ឋលេខាធិការ ក្រសួងអភិវឌ្ឍន៍ជនបទ ( ក្រ.អ.ជ.ប) | អនុប្រធាន |
| ៤. ឯកឧត្តម **សៅ ជីវន្ត** | រដ្ឋលេខាធិការ ក្រសួងអភិវឌ្ឍន៍ជនបទ | អនុប្រធានអចិន្ត្រៃយ៍ |
| ៥. ឯកឧត្តម **លី ប៊ុនម៉េង** | អនុរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ និងជាអនុប្រធានទី៣ នៃក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ( ក.ក.ជ) | សមាជិក |
| ៦. ឯកឧត្តម **ហេង សុខគង់** | អនុរដ្ឋលេខាធិការ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ៧. ឯកឧត្តម **ជួប សំអាត** | អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ ក្រ.អ.ជ.ប | សមាជិក |
| ៨. ឯកឧត្តម **ចាន់ ដារ៉ុង** | អគ្គនាយកបច្ចេកទេស ក្រ.អ.ជ.ប | សមាជិក |
| ៩. លោក **ជា សំណាង** | ប្រធាននាយកដ្ឋានថែទាំសុខភាពជនបទ ក្រ.អ.ជ.ប | សមាជិក |
| ១០. លោក **ម៉ៅ សារ៉ាយ** | ប្រធាននាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ ក្រ.អ.ជ.ប | សមាជិក |
| ១១. លោក **ម៉ា សុវណ្ណា** | ប្រធាននាយកដ្ឋានផែនការ និងទំនាក់ទំនងសាធារណៈ ក្រ.អ.ជ.ប | សមាជិក |
| ១២. លោក **បាន សុម៉ារ៉ា** | ប្រធាននាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញវត្ថុ ក្រ.អ.ជ.ប | សមាជិក |
| ១៣. លោក **សុខ មុនីរតនា** | ប្រធាននាយកដ្ឋានទឹកស្អាត និងអនាម័យ ក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ១៤. លោក **កុល ហៀ** | អនុប្រធាននាយកដ្ឋានការពារសុខភាព ក្រសួងសុខាភិបាល | សមាជិក |
| ១៥. លោក **ប៉ែន ធីរុង្គ** | អនុប្រធានទី ១ នាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១៦. លោក **អ៊ុល ណាក់** | អនុប្រធាននាយកដ្ឋានគោលនយោបាយសម្របសម្រួលហិរញ្ញប្បទាន សហប្រតិបត្តិការអភិវឌ្ឍន៍ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ១៧. លោកស្រី **ឃ្លោក ប៉េងចុល** | អនុប្រធាននាយកដ្ឋានស្ត្រី និងសុខភាព ក្រសួងកិច្ចការនារី | សមាជិក |
| ១៨. លោក **កាំង លាងអ៊ី** | អនុប្រធាននាយកដ្ឋានផែនការសេដ្ឋកិច្ច ក្រសួងផែនការ | សមាជិក |
| ១៩. លោក **វន ស៊ីថា** | អនុប្រធាននាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ | សមាជិក |
| ២០. លោកស្រី **ជា ផល្លីន** | អគ្គនាយករងវិទ្យុជាតិកម្ពុជា ក្រសួងព័ត៌មាន | សមាជិក |
| ២១. លោក **ទិត សាខន** | អនុប្រធាននាយកដ្ឋានសុខភាពសិក្សា ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ២២. បណ្ឌិត **Mohd Nasir Hassan** | តំណាងអង្គការ WHO-Cambodia | សមាជិក |
| ២៣. លោកស្រី **Isabelle Austin** | តំណាងអង្គការ UNICEF | សមាជិក |

| | | |
|---|---|---|
| ២៤. លោកស្រី **Karin S. Bloom** | តំណាងធនាគារអភិវឌ្ឍន៍អាស៊ី (ADB) | សមាជិក |
| ២៥. លោក **Lachlan Pontifex** | តំណាងអង្គការ AUSAID | សមាជិក |
| ២៦. លោកស្រី **Ronit Kirshner Gerard** | តំណាងអង្គការ USAID | សមាជិក |
| ២៧. លោក **Shingo Morihata** | តំណាងអង្គការ JICA | សមាជិក |
| ២៨. លោក **Manfred Staab** | តំណាងអង្គការ ECOSORN (EU) | សមាជិក |
| ២៩. លោក **Marc Hall** | តំណាងអង្គការ RDI | សមាជិក |

**ប្រការ ៣ : ក.ក.ប.ធ.ទ.អ** មានភារកិច្ចសំខាន់ៗ ដូចតទៅ :

**១. ការណែនាំលើផ្នែកគោលនយោបាយ**

- ធានាភាពជាម្ចាស់ថ្នាក់ជាតិ និងការទទួលស្គាល់នូវតួនាទីដឹកនាំ របស់ក្រសួងអភិវឌ្ឍន៍ជនបទ ក្នុងការអភិវឌ្ឍន៍វិស័យផ្គត់ផ្គង់ទឹកស្អាត អនាម័យបរិស្ថាន និងអនាម័យផ្ទាល់ខ្លួន (RWSSH) ។
- គាំទ្រកិច្ចខិតខំស្វែងរកមតិគាំទ្រ ពីក្រសួងអភិវឌ្ឍន៍ជនបទ ដើម្បីធានាថា រាជរដ្ឋាភិបាលបានផ្តល់អាទិភាពខ្ពស់ដល់វិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ដើម្បីដោះស្រាយបញ្ហាទាំងឡាយ ក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ។
- ពិនិត្យឡើងវិញនូវគោលនយោបាយស្តីពីវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ និងលិខិតបទដ្ឋានគតិយុត្តិនានា ដែលទាក់ទងនឹងការធ្វើឱ្យប្រសើរឡើង នូវវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ។
- ផ្តល់មតិយោបល់ផ្សេងៗ ដើម្បីកែទំរង់លិខិតបទដ្ឋានគតិយុត្តិ ក្នុងការលើកទឹកចិត្ត និងបង្កើនការចូលរួមរបស់ផ្នែកឯកជន ក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ។
- លើកកំពស់ភាពសុខដុមរមនាកម្ម លើយុទ្ធសាស្ត្រនានាក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ និងធានាប្រសិទ្ធភាព ស្របនឹងគោលនយោបាយវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ និងគោលការណ៍ជាយុទ្ធសាស្ត្រនានា ។

**២. យុទ្ធសាស្ត្រ និង ថវិកា**

- តាមដាន និងពិនិត្យឡើងវិញនូវសូចនាករនៃការតាមដានរួមគ្នា (JMI) ដើម្បីឱ្យមានភាពស្របគ្នាជាមួយនឹងវដ្តនៃផែនការ និងរបាយការណ៍របស់គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ (GDCC) ។
- គាំទ្រការអភិវឌ្ឍន៍យុទ្ធសាស្ត្រវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ដែលលើកកំពស់ការធ្វើឱ្យសម្រេចនូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា គោលដៅផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងចក្ខុវិស័យគោលនយោបាយជាតិ ស្តីពីវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ និងបង្ហាញពីតម្រូវការអភិវឌ្ឍន៍ធនធានមនុស្សរបស់ស្ថាប័ន អង្គការ និងបុគ្គលិកនៅគ្រប់កម្រិត នៅក្នុងបរិបទនៃសកម្មភាពកំណែទំរង់សេវាសាធារណៈ ដែលកំពុងបន្ត ។

- កំណត់នូវការគាំទ្រផ្សេងៗ និងគំរូនានាដែលពាក់ព័ន្ធដោយផ្ទាល់នឹងដំណើរការអភិវឌ្ឍ ការអនុវត្តន៍ ការផ្តល់ថវិកា ការតាមដាន និងពិនិត្យឡើងវិញ នូវយុទ្ធសាស្ត្រវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ។
- តាមដាន និងដឹកនាំដំណើរការរៀបចំផែនការវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ការអនុវត្តន៍ផែនការ និងពិនិត្យឡើងវិញនូវដំណើរការវិស័យនេះ ដោយរួមបញ្ចូលទាំងសកម្មភាព សុខដុមរមនាកម្ម និងភាពរលូននៃអន្តរាគមន៍ផ្សេងៗ ដើម្បីគាំទ្រគោលដៅ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងចក្ខុវិស័យគោលនយោបាយជាតិ ស្តីពីវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ។
- ផ្តល់ការណែនាំ ពិគ្រោះ និងសម្របសម្រួលការគាំទ្របច្ចេកទេស សម្រាប់អភិវឌ្ឍន៍ផែនការវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ និងការរៀបចំគម្រោង ឱ្យស្របគ្នាជាមួយនឹងគោលការណ៍ :
  (១) ផ្តោតលើការកាត់បន្ថយភាពក្រីក្រ សមភាពយេនឌ័រ ចីរភាពបរិស្ថាន និងគោលការណ៍សមធម៌ ។
  (២) លើកកំពស់ការផ្លាស់ប្តូរទម្លាប់ តាមរយៈយុទ្ធសាស្ត្របញ្ជ្រាបសកម្មភាពនេះ ទៅក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាត អនាម័យបរិស្ថាន និងអនាម័យផ្ទាល់ខ្លួន ។
- កំណត់ធនធានថវិកា និងគម្លាត កំណត់ដៃគូអភិវឌ្ឍន៍ដែលគាំទ្រថវិកា និងស្វែងរកមតិគាំទ្រ សម្រាប់ការកើនឡើងនៃការវិភាជន៍ធនធានថវិកាជាតិក្នុងការគាំទ្រ និងលើកកំពស់អនាម័យបរិស្ថាន អនាម័យផ្ទាល់ខ្លួន និងទឹកស្អាត ។

## ៣. ការកសាងសមត្ថភាព

- អភិវឌ្ឍយុទ្ធសាស្ត្រកសាងសមត្ថភាពដ៏សមស្របមួយ ដោយផ្អែកលើការវាយតម្លៃពីតម្រូវការ និងតួនាទីភារកិច្ចជាក់ស្តែង ក្នុងការអភិវឌ្ឍសមត្ថភាពនៅកម្រិតជាតិ កម្រិតអង្គភាព និងកម្រិតបុគ្គលម្នាក់ៗ។
- កំណត់ និងឯកភាពលើកម្មវិធីជាតិមួយ ដែលដឹកនាំដោយរាជរដ្ឋាភិបាលកម្ពុជា សម្រាប់ផ្តល់ជំនួយបច្ចេកទេស លើវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ។
- បង្កើត និងរៀបចំសូចនាករតាមដាន ដែលនឹងបង្ហាញពីការរីកចំរើនឆ្ពោះទៅរកការអភិវឌ្ឍន៍សមត្ថភាព។

## ៤. ប្រសិទ្ធភាពជំនួយ

- លើកកំពស់ប្រសិទ្ធភាពជំនួយ ដោយធ្វើឱ្យមានភាពរលូន ក្នុងការអនុវត្តន៍គម្រោង ក្នុងលទ្ធផលផែនការសកម្មភាព និងក្នុងការកំណត់ និងសម្របសម្រួលសកម្មភាពផ្សេងៗជាច្រើន នៅក្នុងបរិបទនៃសុខដុមរមនាកម្ម របស់រាជរដ្ឋាភិបាលកម្ពុជា ។ ប្រសិទ្ធភាពនៃជំនួយផ្អែកលើ (១) ផែនទីផ្លូវឆ្ពោះទៅកាន់យុទ្ធសាស្ត្រទូលំទូលាយមួយ ដែលដើរស្របគ្នាជាមួយនឹងយុទ្ធសាស្ត្រវិមជ្ឈការ និងវិសហមជ្ឈការ (២) ការពិភាក្សារិះរកយន្តការល្អនានា ធ្វើការ និងវិភាគរួមគ្នាលើដំណើរការវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ដោយប្រើប្រាស់ :
  - យន្តការសម្របសម្រួលនៃកិច្ចសហប្រតិបត្តិការបច្ចេកទេស
  - ការតាមដាន និងប្រើប្រាស់រចនាសម្ព័ន្ធដែលមានស្រាប់នៅក្នុងបរិបទការងារ
  - ការកសាងសមត្ថភាពដ៏ទូលំទូលាយ និងការអនុវត្តន៍គោលការណ៍ប្រតិបត្តិនានា ។

## ៥. របាយការណ៍ និង ការត្រួតពិនិត្យឡើងវិញ

- រៀបចំផែនការសកម្មភាពប្រចាំឆ្នាំ និងរបាយការណ៍រីកចំរើន ជូនគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ដោយគោរពតាមសូចនាករតាមដានរួមគ្នា (JMI) និងទស្សនទាននៃភាពសុខដុមរមនាកម្ម ភាពរលូនជាមួយគ្នា និងលទ្ធផលផែនការសកម្មភាព ។
- ផ្តល់មតិយោបល់ក្នុងរបាយការណ៍រីកចំរើន នៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងចូលរួមពង្រឹងរបាយការណ៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងពិនិត្យតាមដាន ដោយកំណត់បន្ថែម នូវការងារវិភាគលើវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ទិន្នន័យលើវិស័យនេះ និងជាពិសេសគឺផ្តល់ការណែនាំទៅក្រសួងអភិវឌ្ឍន៍ជនបទ ពីលទ្ធផលទាំងនេះ ដោយជម្រាបជូនទៅវិទ្យាស្ថានជាតិស្ថិតិ អំពីការបង្កើនប្រព័ន្ធគ្រប់គ្រងព័ត៌មានវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ដោយធ្វើការឯកភាពគ្នាលើនិយមន័យនានា នៃវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ។
- ពិនិត្យឡើងវិញនូវតួនាទី របស់ **ក.ក.ប.ផ.ទ.អ** នៅពេលវេលាមួយដែលឆ្លើយតបនឹងប្រតិទិននៃការធ្វើរបាយការណ៍របស់គណៈកម្មាធិការសម្របសម្រួលរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ (GDCC) ។ យោបល់ផ្សេងៗ អាចនឹងត្រូវបានរៀបចំឡើង សម្រាប់ធ្វើវិសោធនកម្មទៅលើ :
    ១. ទំហំ និងសមាសភាព នៃក្រុមការងារបច្ចេកទេស
    ២. តម្រូវការនានា នៃការរៀបចំអនុក្រុមការងារបច្ចេកទេស និង
    ៣. ការសម្របសម្រួលការងារផ្សេងៗ ។

**ប្រការ ៤:** កិច្ចដំណើរការរបស់ **ក.ក.ប.ផ.ទ.អ** មានដូចតទៅ :

១. សមាជិក **ក.ក.ប.ផ.ទ.អ** ត្រូវចូលរួមប្រជុំរៀងរាល់ ៣ ខែម្តង ឬតាមការអញ្ជើញរបស់ប្រធាន **ក.ក.ប.ផ.ទ.អ** ក្នុងករណីពិសេស ។

២. ប្រធាន **ក.ក.ប.ផ.ទ.អ** មានសិទ្ធិបង្កើតអនុក្រុមការងារដើម្បីឆ្លើយតបទៅនឹងករណីចាំបាច់ណាមួយនៅក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ក្រោយពីមានការឯកភាពគ្នាក្នុងចំណោមសមាជិក **ក.ក.ប.ផ.ទ.អ** ។

៣. **ក.ក.ប.ផ.ទ.អ** ត្រូវរាយការណ៍ពីវឌ្ឍនភាព នៃវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ជូនទៅគណៈកម្មាធិការសម្របសម្រួលនៃរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ (GDCC) តាមរយៈក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) ។

៤. កិច្ចប្រជុំនៃ **ក.ក.ប.ផ.ទ.អ** ត្រូវដឹកនាំដោយប្រធាន ឬអនុប្រធានមួយរូបដែលមានការប្រគល់ភារកិច្ចពីប្រធាន និងប្រធានសម្របសម្រួលភាគីដៃគូអភិវឌ្ឍន៍ ។ លេខាធិការដ្ឋាននៃ **ក.ក.ប.ផ.ទ.អ** មានភារកិច្ចរៀបចំកិច្ចប្រជុំរបស់ **ក.ក.ប.ផ.ទ.អ** ។

**ប្រការ ៥ :** ត្រូវបានបង្កើតលេខាធិការដ្ឋាននៃ **ក.ក.ប.ផ.ទ.អ** ដើម្បីសម្របសម្រួលដំណើរការការងារប្រចាំថ្ងៃរបស់ **ក.ក.ប.ផ.ទ.អ** ដោយសហការយ៉ាងជិតស្និទ្ធជាមួយនឹងបណ្តាដៃគូអភិវឌ្ឍន៍ ។ សមាសភាពរបស់លេខាធិការដ្ឋាននៃ **ក.ក.ប.ផ.ទ.អ** មាន :

| | | |
|---|---|---|
| ១. ឯកឧត្តម **សៅ ជីវន្ត** | រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | ប្រធាន |
| ២. លោក **ម៉ៅ សារ៉ាយ** | ប្រធាននាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ | អនុប្រធាន |
| ៣. លោក **ជា សំណាង** | ប្រធាននាយកដ្ឋានថែទាំសុខភាពជនបទ | អនុប្រធាន |
| ៤. លោក **ជ្រាយ ប៊ុម** | អនុប្រធាននាយកដ្ឋានថែទាំសុខភាពជនបទ | សមាជិក |
| ៥. លោក **ឡៅប កាណូវ៉ា** | អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍សហគមន៍ | សមាជិក |
| ៦. លោក **អេវ សម្បត្តិ** | អនុប្រធាននាយកដ្ឋានថែទាំសុខភាពជនបទ | សមាជិក |
| ៧. លោក **ស្រ៊ិន ពុទ្ធី** | អនុប្រធាននាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ | សមាជិក |
| ៨. លោក **ប៊ុន យាង** | ប្រធានការិយាល័យ នាយកដ្ឋានថែទាំសុខភាពជនបទ | លេខាធិការ |
| ៩. កញ្ញា **ហ៊ឹម សុមុនី** | មន្ត្រីនាយកដ្ឋានបណ្តុះបណ្តាល និងស្រាវជ្រាវ | លេខាធិការ |

**ប្រការ ៦ :** លេខាធិការដ្ឋាននៃ **ក.ក.ប.ផ.ទ.អ** មានភារកិច្ចដូចតទៅ :

១. ជាជំនួយការឱ្យប្រធានក្រុមការងារបច្ចេកទេសវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ក្នុងការសម្របសម្រួល និងដំណើរការការងាររដ្ឋបាលប្រចាំថ្ងៃ របស់ **ក.ក.ប.ផ.ទ.អ** ។

២. រៀបចំផែនការការងារប្រចាំឆ្នាំ សម្រាប់ **ក.ក.ប.ផ.ទ.អ** និងរបាយការណ៍រីកចំរើនរបស់វិស័យនេះ ដើម្បីដាក់ជូនទៅសមាជិក **ក.ក.ប.ផ.ទ.អ** ពិនិត្យ និងអនុម័ត ។

៣. សម្របសម្រួលកិច្ចដំណើរការប្រជុំរបស់ **ក.ក.ប.ផ.ទ.អ** មានជាអាទិ៍ ការរៀបចំរបៀបវារៈនៃកិច្ចប្រជុំ ការធ្វើ និងចែកលិខិតអញ្ជើញ ការធ្វើកំណត់ហេតុនៃកិច្ចប្រជុំ និងការរៀបចំឯកសារ និងលិខិតស្នាមរដ្ឋបាលផ្សេងៗ ។

៤. ផ្សព្វផ្សាយរបាយការណ៍រីកចំរើននៃវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ជូនដល់សមាជិកសមាជិកា **ក.ក.ប.ផ.ទ.អ** ដែលជាតំណាងស្ថាប័នពាក់ព័ន្ធ ចូលរួម និងនៅក្នុងកិច្ចប្រជុំ នៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ (GDCC) ។

៥. ចែករំលែកព័តិមាន ជូនដល់គ្រប់ក្រុមការងារបច្ចេកទេសនានា នៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ (GDCC) ។

៦. តំណាងធនាគារអភិវឌ្ឍន៍អាស៊ី ដែលជាសមាជិក **ក.ក.ប.ផ.ទ.អ** ត្រូវទទួលខុសត្រូវក្នុងការសម្របសម្រួល ទំនាក់ទំនង ជាមួយស្ថាប័នដៃគូអភិវឌ្ឍន៍ ។

**ប្រការ ៧ :** សេចក្តីសម្រេចទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៨ :** ឯកឧត្តម លោក លោកស្រី ដូចមានចែងក្នុងប្រការ ២ និងប្រការ ៥ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ជា សុផារ៉ា

**<u>ចម្លងជូន</u> :**

- **ឯកឧត្តម គាត ឈន់** ឧបនាយករដ្ឋមន្ត្រី
  រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុប្រធានទី ១
  ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងជាប្រធាន GDCC
- ឯកឧត្តមរដ្ឋមន្ត្រី ក្រសួង-ស្ថាប័នពាក់ព័ន្ធ
  *" ដើម្បីជូនជ្រាប "*
- ដូចក្នុងប្រការ ២ និង ប្រការ ៥
  *" ដើម្បីអនុវត្ត "*
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ